បកប្រែក្រៅផ្លូវការ ឯកសារមិនផ្លូវការរបស់អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ **A**

មហាសន្និបាត

ចែកចាយ :
ទូទៅ
A/HRC/12/40
៣១ សីហា ២០០៩
ឯកសារដើម : អង់គ្លេស

ក្រុមប្រឹក្សាសិទ្ធិមនុស្ស
សម័យប្រជុំលើកទីដប់ពីរ
របៀបវារៈចំណុចទី១០

# ការជួយឧបត្ថម្ភផ្នែកបច្ចេកទេស និងការកសាងសមត្ថភាព

## សេវាប្រឹក្សាយោបល់ និងការជួយឧបត្ថម្ភផ្នែកបច្ចេកទេសសំរាប់កម្ពុជា

## របាយការណ៍របស់លោក ស៊ូយ៉ា ស៊ូប៊ីឌី*

## អ្នករាយការណ៍ពិសេស ស្តីពីស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា

* របាយការណ៍នេះត្រូវបានដាក់ជូនក្រោយពេលកំណត់ ដើម្បីបញ្ចូលស្ថានការណ៍ថ្មីៗបំផុតដែលកំពុងវិវត្តន៍ ។

GE.09-15160 (E) 040909

# សេចក្តីសង្ខេប

របាយការណ៍នេះត្រូវបានដាក់ជូនស្របតាមសេចក្ដីសំរេចចិត្តលេខ៩/១៥ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។ អ្នករាយការណ៍ពិសេសបច្ចុប្បន្ន ត្រូវបានតែងតាំងជាផ្លូវការនៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០០៩ ហើយលោកបានបំពេញទស្សនកិច្ចលើកដំបូងរបស់លោកមកកម្ពុជា មួយខែបន្ទាប់ពីនោះគឺចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩ ។ ដោយសារមិនមានពេលវេលាគ្រប់គ្រាន់ ដើម្បីវាយតំលៃឲ្យបានស៊ីជម្រៅអំពីស្ថានការណ៍សិទ្ធិមនុស្សក្នុងប្រទេស ដើម្បីអាចរាយការណ៍អំពីស្ថាន-ការណ៍នេះក្នុងលក្ខណៈមួយគួរជឿបាននោះទើបអ្នករាយការណ៍ពិសេសបានសំរេចថា នៅក្នុងដំណើរទស្សនកិច្ចលើកដំបូងនេះ លោកផ្ដោតការស្វែងយល់ឲ្យបានច្រើនអំពីស្ថានការណ៍ស្មុគ្រស្មាញជាក់-ស្តែងក្នុងប្រទេស ដើម្បីកំណត់ជាថ្មីនូវលក្ខខណ្ឌសំរាប់ការពិភាក្សាប្រកបដោយផ្លែផ្កាជាមួយរដ្ឋាភិបាលអំពីបញ្ហាជាកង្វល់ខាងសិទ្ធិមនុស្ស និងរិះរកមធ្យោបាយផ្សេងៗដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល និងតំណាងសង្គមស៊ីវិល និងសហគមន៍អន្តរជាតិជុំវិញបញ្ហាទាំងនេះ ។

នៅក្នុងដំណើរទស្សនកិច្ចរបស់លោក អ្នករាយការណ៍ពិសេសបានជួបជាមួយនាយករដ្ឋមន្ត្រី និងសមាជិកឯទៀតនៃរាជរដ្ឋាភិបាល សមាជិកសភា និងតុលាការ តំណាងសង្គមស៊ីវិល ព្រមទាំងសមាជិកនៃក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេស និងអ្នកការទូតនានាដែលមានមូលដ្ឋាននៅក្នុងប្រទេស ។ អ្នករាយការណ៍ពិសេសមានការពេញចិត្តចំពោះភាពបើកចំហរនៃដៃគូពិភាក្សារបស់លោកខាងរដ្ឋាភិបាល ដែលចូលរួមពិភាក្សាបញ្ហាសំខាន់ៗដោយមិនលំអៀងនិងមិនប្រកាន់បក្សពួក និងក្នុងគោលបំណងស្វែងរកដំណោះស្រាយផ្សេងៗ ។

បញ្ហាជាច្រើនត្រូវបានលើកឡើង នៅក្នុងពេលនៃដំណើរទស្សនកិច្ចរបស់លោក មានជាអាទិ៍សេរីភាពនៃការសំដែងមតិ ឯករាជ្យភាពនៃតុលាការ សិទ្ធិដីធ្លី និងសិទ្ធិខាងលំនៅដ្ឋាននៅទីក្រុង និងនៅតំបន់ជនបទ និងកំណែទម្រង់ពន្ធនាគារ ។ ក្នុងអាណត្តិរបស់លោក អ្នករាយការណ៍ពិសេសមានបំណងផ្ដោតលើបញ្ហាសំខាន់ៗទាំងនេះ នៅក្នុងដំណើរទស្សនកិច្ចរបស់លោកនៅថ្ងៃខាងមុខ ។

ក្នុងពេលបំពេញបេសកម្ម អ្នករាយការណ៍ពិសេសបានអញ្ជើញរដ្ឋាភិបាលមកបំភ្លឺ អំពីបញ្ហាអាទិភាពរបស់ខ្លួនខាងសិទ្ធិមនុស្ស ដើម្បីលោកអាចលើកមកបញ្ហាអាទិភាពទាំងនេះ មកពិនិត្យពិចារណានៅក្នុងអំឡុងពេលបំពេញអាណត្តិរបស់លោក ។ រដ្ឋាភិបាលនៅមិនទាន់ឆ្លើយតបនឹងសំណើនេះទេ ហើយអ្នករាយការណ៍ពិសេសសង្ឃឹមរងចាំការឆ្លើយតបចំពោះបញ្ហានេះ ដើម្បីបង្កើតកម្មវិធីសកម្មភាពមួយដែលជុំវិញនោះ កិច្ចសហប្រតិបត្តិការអន្តរជាតិ អាចត្រូវបានជំរុញលើកទឹកចិត្ត ។

ដោយរង់ចាំការពិភាក្សាបន្ថែមទៀត ទស្សនកិច្ចដំបូងរបស់អ្នករាយការណ៍ពិសេសនោះគឺទន្ទឹមនឹងកម្ពុជាមានការរីកចំរើនគួរឲ្យកត់សំគាល់ក្នុងវិស័យមួយចំនួនក្តី ដោយសារកេរ្តិ៍ដំណែល ធ្ងន់ធ្ងរដែលបានបន្សល់ទុក និងក្តីរំពឹងខ្ពស់របស់សាធារណជន កម្ពុជានៅតែមានបញ្ហាប្រឈមខ្លាំងមួយចំនួនក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្សក្នុងប្រទេស ហើយអ្នករាយការណ៍ពិសេសមានបំណងធ្វើការងារនេះ ជាមួយរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាទាំងនេះក្នុងន័យស្ថាបនា ។ អ្វីដែលជាសេចក្តីត្រូវការក្នុង ប្រទេសកម្ពុជានោះគឺ រដ្ឋាភិបាលមិនត្រឹមតែត្រូវមានការសន្យាផ្លូវការចំពោះការគោរពសិទ្ធិមនុស្សប៉ុណ្ណោះទេ ប៉ុន្តែរដ្ឋាភិបាលក៏ត្រូវអនុវត្តតាមរយៈសកម្មភាពដែលបានកំណត់ក្នុងវិស័យជាគន្លឹះមួយចំនួន ។ នៅក្នុងវិស័យទាំងនេះ គេត្រូវការឲ្យមានការពិភាក្សាក្នុងន័យស្ថាបនានិងកិច្ចសហប្រតិបត្តិការ រវាងរដ្ឋាភិបាល សង្គមស៊ីវិល និងសហគមន៍អន្តរជាតិ ដែលនៅត្រង់នេះហើយដែលអ្នករាយការណ៍ពិសេសសង្ឃឹមថានឹងរួមចំណែកដ៏សំខាន់នៅឆ្នាំខាងមុខ ។

## I. សេចក្តីផ្តើម

១. របាយការណ៍នេះ ត្រូវបានដាក់ជូនស្របតាមសេចក្តីសំរេចចិត្តលេខ៩/១៥ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលក្នុងនោះក្រុមប្រឹក្សានេះបានសំរេចបន្តអាណត្តិម្តងមួយឆ្នាំ ដល់នីតិវិធីពិសេសស្តីពីស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា តាមរយៈការតែងតាំងអ្នករាយការណ៍ពិសេស មួយរូបឲ្យបំពេញមុខតំណែងចាស់របស់តំណាងពិសេសនៃលោកអគ្គលេខាធិការ អ.ស.ប ។ ខ្ញុំត្រូវបានតែងតាំងដោយក្រុមប្រឹក្សាសិទ្ធិមនុស្សនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៩ ជាអ្នករាយការណ៍ពិសេសថ្មី ដើម្បីធ្វើការក្នុងន័យស្ថាបនាជាមួយរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើឲ្យប្រសើរឡើងថែមទៀតនូវស្ថានការណ៍សិទ្ធិមនុស្សនៅក្នុងប្រទេស និងរាយការណ៍អំពីការអនុវត្តន៍អាណត្តិរបស់ខ្ញុំទៅក្រុមប្រឹក្សាសិទ្ធិមនុស្សនៅក្នុងសម័យប្រជុំលើកទីដប់ពីររបស់ខ្លួន ។ ខ្ញុំបានបំពេញទស្សនកិច្ចលើកដំបូងរបស់ខ្ញុំមកកម្ពុជា ចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩ ។ របាយការណ៍នេះត្រូវបានដាក់ជូនស្របតាមសេចក្តីសំរេចចិត្តលេខ៩/១៥ ។

២. ស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជាបាននិងកំពុងស្ថិតក្នុងកម្មវត្ថុនៃការវិភាគទូលំទូលាយដោយតំណាងពិសេសបួនរូបនៃលោកអគ្គលេខាធិការ អ.ស.ប ព្រមទាំងស្ថាប័នសន្ធិសញ្ញានានា ហើយនៅពេលថ្មីបំផុតនេះ គឺដោយគណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។ ការសង្កេតរបស់ស្ថាប័នទាំងនេះ បានគូសបញ្ជាក់ និងបង្ហាញអំពីបញ្ហាប្រឈមជាច្រើនដែលកម្ពុជាបានជួបប្រទះក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូររបស់បុគ្គលម្នាក់ៗនិងបុគ្គលគ្រប់រូបដែលកំពុងរស់នៅក្នុងដែនដីរបស់ខ្លួន ។ បញ្ហាប្រឈមនៅថ្ងៃខាងមុខគឺមានច្រើន និងមានចរិតលក្ខណៈធ្ងន់ធ្ងរទៀតផង ហើយដៃគូពិភាក្សាខាងរដ្ឋាភិបាលបានផ្តល់ចំណាប់អារម្មណ៍ថា គេមិនអាចគេចវេស

ពីការពិតបានឡើយ ។ ខ្ញុំមានបំណងផ្អែកលើការងារដែលបុព្វាធិការីខ្ញុំបានធ្វើ និងធ្វើការជាមួយរដ្ឋាភិបាល ក្នុងន័យស្ថាបនាក្នុងគោលបំណងធ្វើឲ្យសំរេចលទ្ធផលជាក់ស្តែងសំរាប់ប្រជាជនកម្ពុជា ។

## II. បេសកកម្មលើកដំបូង

៣. គោលបំណងនៃដំណើរទស្សនកិច្ចលើកដំបូងរបស់ខ្ញុំមកប្រទេសកម្ពុជា ដែលបានធ្វើចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩ គឺដើម្បីរៀបចំបង្កើតមូលដ្ឋានមួយសំរាប់ការពិភាក្សាក្នុងន័យស្ថាបនាជាមួយរដ្ឋាភិបាល និងរិះរកកម្មវិធីសកម្មភាពមួយ ដើម្បីធ្វើឲ្យប្រសើរឡើងដល់ស្ថានការណ៍សិទ្ធិមនុស្សនៅក្នុងប្រទេស ។ ខ្ញុំមានបំណងធ្វើឲ្យដំណើរទស្សនកិច្ចលើកដំបូងនេះ ជាឱកាសស្វែងយល់ច្រើនថែមទៀតអំពីស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា ដើម្បីបង្កើតការយោគយល់គ្នាទៅវិញទៅមក និងបណ្តាញទំនាក់ទំនងជាមួយសមាជិកជាន់ខ្ពស់នានានៃរដ្ឋាភិបាល និងស្តាប់មតិយោបល់របស់ប្រជាជនពីគ្រប់ផ្នែកទាំងអស់នៃសង្គម ។

៤. ខ្ញុំមានសេចក្តីរីករាយណាស់ដែលមានបុព្វសិទ្ធិបានជួបប្រជុំជាមួយសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី ឯកឧត្តម ហោ ណាំហុង រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឯកឧត្តម ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្តម ឱម យ៉ិនទៀង ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងសមាជិកជាន់ខ្ពស់ជាច្រើនរូបទៀតនៃរដ្ឋាភិបាល ប្រធានតុលាការកំពូល មេដឹកនាំនៃគណបក្សប្រឆាំងធំមួយក្នុងសភា ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូតមួយចំនួន ដែលមានមូលដ្ឋាននៅរាជធានីភ្នំពេញ ។ ក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេស ប្រធានគណៈមេធាវី ប្រធានក្រុមប្រឹក្សាសារព័ត៌មាន និងតំណាងសង្គមស៊ីវិល ក្រុមជនជាតិដើមភាគតិច និងសហគមន៍ទាំងឡាយដែលរងផលប៉ះពាល់ដោយការបណ្តេញចេញពីដីធ្លីកាលពីពេលកន្លងទៅថ្មីៗនេះ ។

៥. ខ្ញុំរីករាយដែលបានទទួលការរាក់ទាក់ពីសមាជិករដ្ឋាភិបាល និង អង្គការជាដៃគូងទៀតក្នុងសង្គមស៊ីវិល ។ ពួកគេមានឆន្ទៈទូទៅមួយក្នុងការធ្វើការជាមួយខ្ញុំ ដើម្បីធ្វើឲ្យប្រសើរឡើងដល់ស្ថានការណ៍សិទ្ធិមនុស្សនៅក្នុងប្រទេស ហើយខ្ញុំសូមផ្អែកលើកំលាំងជំរុញនៃសហប្រតិបត្តិការនេះ ដើម្បីអនុវត្តអាណត្តិរបស់ខ្ញុំ ។ ខ្ញុំមានឱកាសជួបនិងបានពិភាក្សាក្នុងន័យស្ថាបនា ក្នុងស្មារតីសហប្រតិបត្តិការជាមួយលោកនាយករដ្ឋមន្ត្រី នៅក្នុងអំឡុងនៃដំណើរទស្សនកិច្ចឯកជន របស់លោកមកកាន់ចក្រភពអង់គ្លេស និងអៀរឡង់ខាងជើងក្នុងខែកក្កដា ឆ្នាំ២០០៩ ។ ខ្ញុំសូមអរគុណចំពោះលោកនាយករដ្ឋមន្ត្រីដែលលោកមានឆន្ទៈសហការអនុវត្តអាណត្តិរបស់ខ្ញុំ ។

## III. ចរិតលក្ខណ: និងវិសាលភាពនៃបេសកកម្មលើកដំបូង

៦. នៅក្នុងពេលបំពេញទស្សនកិច្ចលើកដំបូងរបស់ខ្ញុំមកកម្ពុជា ខ្ញុំត្រូវបានគេប្រាប់ឲ្យដឹងអំពីការអភិវឌ្ឍន៍ជាវិជ្ជមានជាច្រើន ដែលកើតមានជាទូទៅចាប់តាំងពីឆ្នាំ១៩៧៩ និងជាពិសេស ក្នុងឆ្នាំ១៩៩៣ រួមទាំងស្ថិរភាពបន្ទាប់ពីសង្គ្រាមជាច្រើនឆ្នាំ ការរីកចំរើនខាងសេដ្ឋកិច្ច និងការរៀបចំបោះឆ្នោតជាទៀងទាត់ រាប់ទាំងការបោះឆ្នោតក្នុងខែកក្កដាឆ្នាំ២០០៨ ដែលប្រព្រឹត្តទៅដោយសន្តិវិធី ។ ខ្ញុំឆ្លៀតឱកាសនេះ គូសបញ្ជាក់ថា បញ្ហាប្រឈមសំរាប់ប្រទេសមួយដូចជាកម្ពុជា គឺត្រូវបន្តដំណើរការកសាងប្រទេសឡើងវិញ ការធ្វើកំណែទម្រង់ និងប្រជាធិបតេយ្យូបនីយកម្មក្នុងភាពប្រាកដប្រជា និងភាពស្មោះត្រង់ ដែលចាំបាច់សំរាប់អនុវត្តបញ្ញត្តិ នៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា ដែលសន្ធិសញ្ញាភាគច្រើនតំណាងឲ្យតំលៃសកល និងជាផ្នែកមួយនៃច្បាប់កម្ពុជា ។ ក្នុងបរិបទនេះ ខ្ញុំមានសេចក្តីរីករាយនឹងកត់សំគាល់ថា អាជ្ញាធរមានឆន្ទៈទទួលស្គាល់អំពីចំណុចខ្វះខាត ហើយចូលរួមក្នុងការពិភាក្សាមួយប្រកបដោយអត្ថន័យ និងក្នុងន័យស្ថាបនាជាមួយខ្ញុំ ពាក់ព័ន្ធនឹងការផ្លាស់ប្តូរ និងកំណែទម្រង់ ។

៧. នៅក្នុងជំនួបប្រជុំរបស់ខ្ញុំជាមួយសមាជិកជាន់ខ្ពស់នានានៃរដ្ឋាភិបាល ខ្ញុំបានគូសបញ្ជាក់អំពីបំណងប្រាថ្នាចង់ឲ្យមានបរិយាកាសសហប្រតិបត្តិការជាមួយផ្នែកសង្គមស៊ីវិល ដែលមានតួនាទីមួយសំខាន់ក្នុងការពិនិត្យពិច័យសកម្មភាពរបស់រដ្ឋាភិបាល និងគូសបញ្ជាក់ពីចំណុចខ្វះខាត ក្នុងលក្ខណ:មួយពិត មិនលំអៀង និងមិនប្រកាន់បក្សពួក ។ សង្គមមួយដែលស្ថិតក្នុងអន្តរកាលនៅឡើយនោះ សង្គមស៊ីវិលបានរួមចំណែកធំធេងក្នុងការជួយបំពេញបន្ថែមលើការងាររបស់រដ្ឋាភិបាលក្នុងវិស័យជាច្រើន បង្កើនជាអតិបរមានូវសក្តានុពលនៃប្រជាជនកម្ពុជា និងធ្វើឲ្យពួកគេយល់ដឹងអំពីការទទួលបាននូវសិទ្ធិមនុស្សរបស់គេ ។

៨. ខ្ញុំបានបញ្ជាក់ថា តាមរយៈការចូលជាសមាជិកអង្គការសហប្រជាជាតិ និងការផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិជាច្រើននោះ កម្ពុជាបានទទួលរ៉ាប់រងអនុវត្តបទដ្ឋានសិទ្ធិមនុស្ស និងបានទទួលសញ្ញាណដែលថា ស្ថានការណ៍សិទ្ធិមនុស្សនៅគ្រប់ប្រទេស គឺជាកង្វល់ធម្មានុរូបរបស់សហគមន៍អន្តរជាតិ ។ ខ្ញុំមានសេចក្តីរីករាយចំពោះការទទួលយកគំនិតនេះ និងការសន្យារបស់រដ្ឋាភិបាលថានឹងធ្វើការជាមួយអាណត្តិរបស់ខ្ញុំ ក្នុងការលើកស្ទួយសិទ្ធិមនុស្សសំរាប់ពេលច្រើនខែឆ្នាំទៅមុខដើម្បីឈានទៅសំរេចបានប្រយោជន៍ជាក់ស្តែងសំរាប់ការការពារសិទ្ធិទាំងនេះនៅក្នុងប្រទេស ។

៩. យ៉ាងណាក៏ដោយ ដោយសារនៅពេលកំពុងសរសេររបាយការណ៍នេះ ខ្ញុំមិនបានទទួលការឆ្លើយតបពីរដ្ឋាភិបាលទាក់ទងនឹងវិស័យអាទិភាពមួយចំនួនសំរាប់ការពិភាក្សា ដែលអាចបង្កើតជាមូល

ដ្ឋានសំរាប់កម្មវិធីសកម្មភាព ។ ចាប់តាំងពីវិលត្រឡប់ពីបំពេញបេសកកម្មនៅកម្ពុជាមក ខ្ញុំបានចូលរួមជាច្រើនជាមួយអ្នកកាន់អាណត្តិនីតិវិធីពិសេសដទៃទៀត ក្នុងការសំដែងកង្វល់អំពីករណីដែលបានរាយការណ៍អំពីការប្តឹងផ្តល់មេដឹកនាំគណបក្សប្រឆាំង ដោយរដ្ឋាភិបាល និងបានស្នើសុំឲ្យផ្តល់ព័ត៌មានបន្ថែមទៀតអំពីករណីទាំងនេះ ។ រដ្ឋាភិបាលមិនទាន់ឆ្លើយតបនៅឡើយទេ ។

## IV. ការសង្កេតជំហ៊ានដំបូង ផ្អែកលើបេសកកម្មលើកដំបូង

### ក. សមិទ្ធិផលធំៗដែលកម្ពុជាសំរេចបាន

១០. កម្ពុជាគឺជាប្រទេសមួយ ដែលនៅបន្តដោះស្រាយរឿងសោកនាដកម្មដែលកើតមានក្នុងអតីតកាល ហើយនៅពេលកន្លងមកនេះមានការរីកចំរើនគួរឲលើកទឹកចិត្ត ។ ប្រព័ន្ធច្បាប់ ប្រព័ន្ធស្ថាប័ន និងប្រព័ន្ធនយោបាយ ត្រូវបានកសាងឡើងវិញពីបាតដៃទទេ ពេលដែលកម្ពុជាបានពង្រឹងខ្លួនជាថ្មីបន្ទាប់ពីឆ្នាំ១៩៧៩ ។ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ប្រទេសនេះបានខិតខំពង្រឹងស្ថិរភាពនយោបាយ ដែលជំរុញឲ្យមានការអភិវឌ្ឍន៍សេដ្ឋកិច្ចរហ័ស ដែលបានរំដោះប្រជាជនជាច្រើនពីភាពក្រីក្រ និងបានដាក់ពួកគេក្នុងទីតាំងមួយដែលអាចអាស្រ័យផលសិទ្ធិរបស់ខ្លួន ខាងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។

១១. មានការបោះឆ្នោតតាមកាលកំណត់ដើម្បីជ្រើសតាំងរដ្ឋាភិបាល ។ ការបោះឆ្នោតទូទៅចុងក្រោយបំផុតបានប្រព្រឹត្តទៅដោយសន្តិវិធីនៅខែកក្កដា ឆ្នាំ២០០៨ ។ មានគណបក្សប្រឆាំងមួយចំនួនក្នុងរដ្ឋសភា ។ អង្គការសង្គមស៊ីវិលជាតិនិងអន្តរជាតិជាច្រើនបាននិងកំពុងប្រតិបត្តិការក្នុងប្រទេសកម្ពុជានៅគ្រប់វិស័យនៃសកម្មភាពមនុស្ស ពួកគេគាំទ្រ ជារឿយធ្វើកិច្ចការជំនួសការងាររបស់រដ្ឋាភិបាល ក្រៅពីនេះពួកគេពិនិត្យពិច័យសកម្មភាពរបស់រដ្ឋាភិបាលផងដែរ ។ មានអង្គការព័ត៌មានផ្សេងៗទាំងផ្នែកបោះពុម្ព ទាំងផ្នែកវិទ្យុ បានផ្តល់សេវារបស់ខ្លួនដល់ប្រជាជនជាភាសាខ្មែរនិងភាសាបរទេស។

១២. ចាប់ពីឆ្នាំ១៩៩៥ មក ប្រជាជនបានទទួលក្នុងកំរិតមួយដែលមិនធ្លាប់មានពីមុនមកនូវសិទ្ធិសេរីភាពខាងការប្រជុំ ការសំដែងមតិ និងការដើរហើរ បើទោះជាប្រជាជនត្រូវសុំច្បាប់អនុញ្ញាត ដើម្បីធ្វើបាតុកម្មជាសាធារណៈក្តី ដែលជួនកាលត្រូវបានបដិសេធដោយផ្អែកលើមូលហេតុសន្តិសុខមិនច្បាស់លាស់ និងការរិតត្បិតតាមទំនើងចិត្តលើការធ្វើដំណើរ ឬការរៀបចំប្រជុំជួនកាលត្រូវគេដាក់កំហិត ។ រដ្ឋាភិបាលបានឆ្លើយតបជាវិជ្ជមានចំពោះអនុសាសន៍ខ្លះ ដែលបានផ្តល់ដោយអតីតតំណាងពិសេសនៃលោកអគ្គលេខាធិការអ.ស.ប ។ ឧទាហរណ៍មួយ គឺការដកទោសគុកពីបទព្រហ្មទណ្ឌសំរាប់ការបរិហារកេរ្តិ៍ ក្នុងឆ្នាំ២០០៦ ។

១៣. រដ្ឋាភិបាលបានជួបប្រទះផងដែរ នូវបញ្ហាមួយស្មុគ្រស្មាញខាងកម្មសិទ្ធិដីធ្លី រួមទាំងដោយការខិតខំប្រឹងប្រែងពង្រឹងសុវត្ថិភាពកាន់កាប់ដីធ្លីរបស់ប្រជាពលរដ្ឋ ។ គំរោងរួមមួយនៃការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីកំពុងដំណើរការអនុវត្តនៅតំបន់ជនបទភាគច្រើន ។ ខ្ញុំមានក្តីរីករាយផងដែរ ដោយឃើញអំពីសមិទ្ធិផលសំរេចបានគួរឲ្យកត់សំគាល់ ដែលរាជរដ្ឋាភិបាលបានធ្វើ ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ ក្នុងគោលបំណងធ្វើអាជីវកម្មផ្លូវភេទ ដោយធ្វើការផ្តន្ទាទោសអ្នកប្រព្រឹត្តល្មើសច្បាប់ប្រឆាំងការជួញដូរ ។ លទ្ធផលវិជ្ជមានដូចគ្នានេះដែរគឺ រដ្ឋាភិបាលបានចាត់វិធានការបិទល្បែងស៊ីសងជាច្រើនកន្លែង បើទោះជាកាស៊ីណូធំៗមួយចំនួននៅបើកដំណើរការក្តី ។ កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បីប្រយុទ្ធប្រឆាំងនឹងជម្ងឺហ៊ីវ/អេដស៍ ទទួលបានការស្ងើចសរសើរជាទូទៅ ក៏ដូចជា កិច្ចខិតខំប្រឹងប្រែងបោសសំអាតមីន ។

១៤. រដ្ឋាភិបាលក៏បានចាត់វិធានការមួយចំនួនទៀត ដែលរីកចំរើនជាលំដាប់ ។ ក្នុងនោះមានវិធានការមួយបានចាត់ឡើងគឺច្បាប់ឆ្នាំ២០០៦ ដែលបានតាក់តែងឡើងដើម្បីប្រឆាំងអំពើហឹង្សាក្នុងគ្រួសារជាពិសេស អំពើហឹង្សាប្រឆាំងនឹងស្ត្រីភេទ ។ វិធានការទាំងឡាយនេះ ទំនងជាមានឥទ្ធិពលខ្លាំងដល់សង្គម ។ រដ្ឋាភិបាលបានបង្កើនការចូលរួមជាមួយស្ថាប័ននានាខាងសន្ធិសញ្ញាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ។ ថ្មីៗនេះ រដ្ឋសភាបានអនុម័តច្បាប់មួយ ដើម្បីផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃអនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ។ ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ និង ក្រសួងសង្គមកិច្ច បានចូលរួមផងដែរក្នុងការពិភាក្សាក្នុងន័យស្ថាបនាជាមួយការិយាល័យឧត្តមស្នង ការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា អំពីវិស័យកំណែទម្រង់ពន្ធនាគារ ប្រព័ន្ធយុត្តិធម៌ និងវិស័យកំណែទម្រង់ឯទៀត ។

១៥. សរុបសេចក្តីទៅ ប្រទេសកម្ពុជាមានការរីកចំរើនគួរឲ្យកត់សំគាល់នៅក្នុងអំឡុងពេលបីទសវត្សរ៍កន្លងមកនេះ ដែលក្នុងនោះពីរទសវត្សន៍ចុងក្រោយមានការជួយជ្រោមជ្រែង ពីសហគមន៍អន្តរជាតិ និងអង្គការសហប្រជាជាតិ ក្នុងការលើកស្ទួយសិទ្ធិមនុស្ស និងធ្វើប្រជាធិបតេយ្យូបនីយកម្ម ប្រព័ន្ធអភិបាលកិច្ច ។ ប្រទេសមួយដែលបានរើខ្លួនចេញពីភ្នក់ភ្លើងសង្គ្រាមមួយដ៏យូរ ហើយមិនយូរប៉ុន្មានឥឡូវនេះក៏មានសេដ្ឋកិច្ចរីកចំរើនខ្ពស់ និងមានស្ថិរភាពនយោបាយ ហើយមានការជឿជាក់ជាខ្លាំងថា ថ្នាក់ដឹកនាំរដ្ឋាភិបាលនឹងធ្វើឲ្យសំរេចសមិទ្ធិផលទាំងនេះ ។

## ខ. បញ្ហាប្រឈម

១៦. ទោះជាមានសមិទ្ធិផលទាំងនេះក្តី ក៏រដ្ឋាភិបាលនៅតែប្រឈមនឹងបញ្ហាមួយក្នុងចំណោមបញ្ហាច្រើនទៀត គឺលទ្ធភាពក្នុងការរក្សាតុល្យភាពរវាងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការការពារសិទ្ធិមនុស្ស

ហើយវាជាវិស័យមួយដែលរដ្ឋាភិបាលត្រូវផ្តោតការយកចិត្តដាក់ពិតប្រាកដ នៅពេលស្វែងរកជំនួយពីសហគមន៍អន្តរជាតិ រួមទាំងពីយន្តការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ។

១៧. ខ្ញុំបានចាប់ផ្តើមពិនិត្យបញ្ហាស្មុគ្រស្មាញខាងជំលោះដីធ្លី និងបានប្រមូលព័ត៌មាន និងការណែនាំពីតួអង្គផ្សេងៗ រួមទាំងសហគមន៍មូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងមន្ត្រីជាន់ខ្ពស់នៃរដ្ឋាភិបាល ។ ការប្រើប្រាស់ដីធ្លីនៅតំបន់ជនបទគឺមានសារៈសំខាន់បំផុត ។ ខ្ញុំសង្កេតឃើញមានការផ្តាច់ពីគ្នារវាងច្បាប់ជាតិដែលទទួលស្គាល់សិទ្ធិប្រជាពលរដ្ឋជាម្ចាស់លើដីធ្លី និងបង្កើតគោលការណ៍ច្បាស់លាស់ដើម្បីធានាការពារដីធ្លី និងការដណ្តើមដីធ្លី និងការផ្លាស់ប្តូរកម្មសិទ្ធិដីធ្លីទំនងជាកើតមានទូទៅនៅទីក្រុង និងនៅតំបន់ជនបទ ។ ក្នុងបរិបទនៃការរីកចំរើនសេដ្ឋកិច្ចបច្ចុប្បន្នដែល តំលៃដីឡើងថ្លៃខ្ពស់ និងការជួញដូរដីធ្លី ការបណ្តេញប្រជាពលរដ្ឋសហគមន៍ ដែលពួកគាត់បានរស់នៅទីនោះរយៈពេលជាច្រើនឆ្នាំ ក្នុងរូបភាពជាការតាំងលំនៅថ្មីក្រៅផ្លូវការ បានក្លាយទៅជារឿងធម្មតាទៅហើយៗភាគច្រើនមិនមានការផ្តល់សំណងសមរម្យ ដើម្បីបើកច្រកសំរាប់ការអភិវឌ្ឍន៍មួយដែលគំហុក ។ ខ្ញុំមានកង្វល់ថា និន្នាការនេះនឹងធ្វើឲអន្តរាយដល់នីតិរដ្ឋ និងធ្វើឲ្យប្រជាពលរដ្ឋបាត់បង់របរចិញ្ចឹមជីវិត ។

១៨. ខ្ញុំបានដឹងដែរថា នៅតំបន់ជនបទ សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍ជនបទ ជារឿយៗមិនមានមធ្យោបាយការពារដីធ្លីរបស់ខ្លួនមិនឲ្យបុគ្គលមានអំណាចដណ្តើមយក ឬសម្បទានដី ឬសម្បទានរ៉ែឡើយ ។ ចំណាប់អារម្មណ៍ដំបូងរបស់ខ្ញុំគឺ សេចក្តីត្រូវការពង្រឹងការអនុវត្តន៍ច្បាប់ភូមិបាលក្នុងលក្ខណៈត្រឹមត្រូវក្នុងវិស័យនេះ ដោយប្រព័ន្ធរដ្ឋបាល និងប្រព័ន្ធតុលាការ ។ វាក៏ជាសេចក្តីត្រូវការផងដែរ ដើម្បីបញ្ជាក់ច្បាស់អំពីសនិទានភាព និងដំណើរការនៃការបណ្តេញចេញ និងការតាំងលំនៅថ្មី ប្រហែលជាតាមរយៈការអនុម័តគោលការណ៍ណែនាំថ្នាក់ជាតិ ដែលចាប់បង្ខំឲ្យអនុវត្ត និងត្រួសត្រាយផ្លូវ ដើម្បីធានាសុវត្ថិភាពកាន់កាប់ដីធ្លីសំរាប់ប្រជាពលរដ្ឋដែលងាយរងគ្រោះបំផុត ។ នេះជាវិស័យមួយ ដែលខ្ញុំរីករាយនឹងផ្តល់ជាមតិណែនាំ និងព្យាយាមពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការស្វែងរកដំណោះ ស្រាយរយៈពេលវែងចំពោះបញ្ហាលំបាកស្មុគ្រស្មាញនេះ ។

១៩. បញ្ហាមួយទៀតដែលលេចធ្លោជាងគេ នៅក្នុងពេលបំពេញទស្សនកិច្ចរបស់ខ្ញុំ គឺការកើតមានជាបន្តបន្ទាប់នូវការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ និងការផ្សាយព័ត៌មានមិនពិតដែលរដ្ឋាភិបាលជាអ្នកប្តឹង ឬបានប្តឹងក្នុងនាមរដ្ឋាភិបាលប្រឆាំងនឹងសមាជិកគណបក្សប្រឆាំងនិងអ្នកឯទៀត ដែលរិះគន់ការអនុវត្តន៍ ឬគោលនយោបាយសាធារណៈ ។ មានការប្រកាសទោសមួយចំនួន ។ បុរសពីរនាក់ ម្នាក់ជាប្រធានអង្គការក្រៅរដ្ឋាភិបាលមួយ និងម្នាក់ទៀតជាអ្នកនិពន្ធកាសែត អ្នកទាំងពីរនាក់នេះជិតដិតជាមួយគណបក្សប្រឆាំងធំមួយ ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារ ។ មេដឹកនាំជាន់ខ្ពស់មួយរូប

នៃគណបក្សដដែលនេះ អ្នកស្រី មូរ សុខហួរ ត្រូវបានរដ្ឋសភាដកអភ័យឯកសិទ្ធិ និងផ្តន្ទាទោសចំពោះការប្តឹងបរិហារកេរ្តិ៍លោកនាយករដ្ឋមន្ត្រី ។ អ្នកស្រីមិនត្រូវបានគេផ្តល់ឱកាសឲ្យបង្ហាញករណីរបស់គាត់នៅក្នុងរដ្ឋសភា នៅមុនការចាត់វិធានការប្រឆាំងនឹងគាត់ទេ ។ អ្នកគាំទ្រគាត់ ត្រូវបានកំលាំងសន្តិសុខដេញចេញក្រៅអគារសភា ហើយឯកអគ្គរដ្ឋទូតបរទេសដែលមានបំណងចូលអចិន្ត្រៃយ៍ ក្នុងសាលប្រជុំសភា មិនត្រូវបានគេអនុញ្ញាតឲ្យចូលឡើយ ។ រិតតែអាក្រក់ជាងនេះគឺ មេធាវីរបស់អ្នកស្រីក៏ស្ថិតក្នុងការគាបសង្កត់ផងដែរ ដោយសារគាត់និយាយដោយចំហរអំពីករណីនេះជាសាធារណៈ ហើយបានដកខ្លួនចេញជាយថាហេតុ ទុកឲ្យអ្នកស្រី មូរ សុខហួរ គ្មានមេធាវីការពារ ។

២០. នេះជានិន្នាការរំខានមួយ ដែលប្រសិនជានៅតែបណ្តោយឲ្យកើតមានតទៅទៀត វាអាចនឹងធ្វើឲ្យអន្តរាយធ្ងន់ធ្ងរដល់ការអនុវត្តន៍សិទ្ធិដែលធានាការពារដោយរដ្ឋធម្មនុញ្ញ គឺសេរីភាពខាងការសំដែងមតិ ដែលសំខាន់ចាំបាច់ចំពោះប្រសិទ្ធភាពសារព័ត៌មាន សេរីភាព ពហុបក្ស ភាពទីទៃពីគ្នា និងការជជែកគ្នាតាមបែបប្រជាធិបតេយ្យ ។ ខ្ញុំបានពិភាក្សាអំពីកង្វល់ទាំងនេះជាមួយលោកនាយរដ្ឋមន្ត្រី ហើយសង្ឃឹមថានឹងបន្តការពិភាក្សាជាមួយគាត់ និងរដ្ឋាភិបាល ដើម្បីជំរុញឲ្យមានថែមទៀតនូវបរិយាកាសអត់ឱន ដើម្បីប្រសិទ្ធភាពប្រជាធិបតេយ្យ នោះគឺការជជែកគ្នាដោយសេរី ដោយគោរពគ្នា និងមានមតិជំទាស់ ។ ការប្រព្រឹត្តទៅលើមេធាវីរបស់អ្នកស្រី មូរ សុខហួរ ទំនងជាមានផលប៉ះពាល់មិនល្អទៅលើឯករាជ្យភាព និងសេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈច្បាប់ ។

២១. បញ្ហាប្រឈមសំរាប់ប្រទេសមួយដូចជាកម្ពុជា គឺការបន្តដំណើរការកំណែទម្រង់ និងប្រជាធិបតេយ្យូបនីយកម្មក្នុងភាពប្រាកដប្រជា និងភាពស្មោះត្រង់ ដែលចាំបាច់សំរាប់អនុវត្តបញ្ញត្តិនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា ដែលសន្ធិសញ្ញាភាគច្រើនតំណាងឲ្យតំលៃសកល និងជាផ្នែកមួយនៃច្បាប់កម្ពុជា ។ គោលបំណងរបស់ខ្ញុំជាអ្នករាយការណ៍ពិសេស គឺមិនមែនគ្រាន់តែរិះគន់រដ្ឋាភិបាលអំពីចំណុចខ្វះខាតរបស់ខ្លួននោះទេ ប៉ុន្តែគឺផ្តល់មតិណែនាំផ្នែកជំនាញ ឯករាជ្យ ហើយពិតមិនលំអៀងដល់រដ្ឋាភិបាល និងធ្វើការជាមួយរដ្ឋាភិបាល ដើម្បីលើកស្ទួយនិងការពារសិទ្ធិមនុស្ស ពង្រឹងនីតិរដ្ឋ និងពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិសំរាប់គោលដៅនោះ និងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល និងតំណាងសង្គមស៊ីវិលក្នុងបញ្ហានេះ ។ ខ្ញុំមានកង្វល់អំពីស្ថានការណ៍ដុនដាបនៃការបណ្តេញចេញពីដីធ្លី និងសេរីភាពខាងការសំដែងមតិ / ការបរិហារកេរ្តិ៍ ហើយសង្ឃឹមរីករាយនឹងធ្វើការជាមួយរដ្ឋាភិបាល និងតំណាងសង្គមស៊ីវិល ដើម្បីដោះស្រាយបញ្ហាទាំងនេះ ។

## V. ទិសដៅនៅថ្ងៃខាងមុខ

២២. ខ្ញុំមានបំណងបើកទំព័រថ្មីនៃកិច្ចសហប្រតិបត្តិការ ក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស នៅកម្ពុជា ។ ខ្ញុំចាត់ទុកអាណត្តិរបស់ខ្ញុំថាជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់អង្គការសហប្រជាជាតិ ដើម្បីផ្តល់ការជួយឧបត្ថម្ភដល់ប្រជាជន និងរដ្ឋាភិបាលកម្ពុជា ។ ចំណាប់អារម្មណ៍ដែលខ្ញុំមាននៅក្នុងអំឡុងពេលបំពេញបេសកកម្ម លើកដំបូងរបស់ខ្ញុំមកកម្ពុជានោះគឺថា រដ្ឋាភិបាលមានឆន្ទៈចង់ធ្វើការជាមួយខ្ញុំ ជាមួយសង្គមស៊ីវិល និងសហគមន៍អន្តរជាតិ ក្នុងការដោះស្រាយបញ្ហាសិទ្ធិមនុស្សមួយចំនួនដែលប្រទេសជាតិកំពុងជួបប្រទះ ។ ខ្ញុំបានស្នើសុំផ្តល់ការជួយឧបត្ថម្ភរបស់ខ្ញុំដល់រដ្ឋាភិបាលក្នុងការកំណត់បញ្ហា និងក្នុងការដោះស្រាយបញ្ហាទាំងនោះ ក្នុងន័យស្ថាបនា ហើយខ្ញុំសង្ឃឹមរងចាំទទួលការឆ្លើយតបជាវិជ្ជមាន ។

២៣. ខ្ញុំសង្ឃឹមថារដ្ឋាភិបាល និងតំណាងសង្គមស៊ីវិលនឹងចាត់ទុកខ្ញុំជាដៃគូមួយមានឆន្ទៈក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីធ្វើឲ្យប្រសើរឡើងដល់ស្ថានការណ៍សិទ្ធិមនុស្សនៅក្នុងប្រទេស ។ ខ្ញុំក៏ជាអ្នកស្តាប់មួយរូបដែលមានឆន្ទៈ អំពីកង្វល់របស់ភាគីទាំងសងខាង និងផ្តល់ជូននូវសេវារបស់ខ្ញុំជាអ្នករាយការណ៍ពិសេសមួយរូបដែលឯករាជ្យ និងមិនលំអៀង របស់អង្គការសហប្រជាជាតិ ដែលពាំនាំយកបទពិសោធន៍ការងាររបស់ខ្ញុំក្នុងវិស័យច្បាប់អន្តរជាតិ ច្បាប់សិទ្ធិមនុស្ស និងច្បាប់រដ្ឋធម្មនុញ្ញ ដែលមានរយៈពេលជាច្រើនឆ្នាំនៅបណ្តាប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ ។ គោលដៅរបស់ខ្ញុំគឺធ្វើការដោយសុច្ចរិត ដោយរំពឹងថានឹងបានទទួលដូចគ្នានេះពីភាគីដទៃទៀត និងតំកល់ទុកការវិនិច្ឆ័យទទួលស្គាល់លទ្ធផលសំរេចបាន និងការទទួលស្គាល់ភាពកំសោយដោយគ្មានការលាក់លាម ប្រសិនជាចាំបាច់ ប៉ុន្តែនៅក្នុងន័យស្ថាបនា ។

២៤. ខ្ញុំមានការពេញចិត្តចំពោះការងារកំពុងអនុវត្ត ដោយការិយាល័យឧត្តមស្នងការ អង្គការសហ-ប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា និង ដោយសង្គមស៊ីវិលក្នុងការលើកស្ទួយសិទ្ធិមនុស្សនៅកម្ពុជា និងចំពោះកំរិតនៃកិច្ចសហប្រតិបត្តិការជាមួយខ្ញុំ នៅក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចរបស់ខ្ញុំ ។ ខ្ញុំមានបំណងសហការក្នុងន័យស្ថាបនាជាមួយការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សប្រចាំកម្ពុជា ក្នុងការអនុវត្តន៍អាណត្តិរបស់ខ្ញុំ ហើយសង្ឃឹមថារដ្ឋាភិបាលនឹងបន្តធ្វើការជាមួយការិយាល័យនេះ នៅក្នុងវិស័យជាគន្លឹះនិងដែលរសើបមួយចំនួន តាមរយៈទិសដៅមួយដែលផ្អែកលើការពិភាក្សា កិច្ចសហប្រតិបត្តិការ និងការរិះគន់ក្នុងន័យស្ថាបនា ព្រោះថាការធ្វើដូច្នេះ អាចជួយសម្រួលយ៉ាងច្រើន ដល់ការងាររបស់ខ្ញុំ និងការងាររបស់យន្តការសិទ្ធិមនុស្សអង្គការសហប្រជាជាតិទាំងមូល ។

VI. សេចក្តីសន្និដ្ឋាន

២៥. ក្នុងការសន្និដ្ឋាន ខ្ញុំជឿថាការលើកស្ទួយ និងការការពារសិទ្ធិមនុស្សនៅកម្ពុជាអាស្រ័យលើការធ្វើឲ្យរីកចំរើនពិតប្រាកដ និងជាដុំកំភួនក្នុងការពង្រឹងនីតិរដ្ឋ ការបែងចែកឲ្យដាច់ស្រឡះពីគ្នាថែមទៀតរវាងអំណាចធំៗទាំងបីរបស់រដ្ឋាភិបាល ការការពារឯករាជ្យភាពនៃតុលាការ រាប់ទាំងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងដោះស្រាយបញ្ហាមួយចំនួនដូចជាជំលោះដីធ្លី នីទណ្ឌភាព និងការគ្រប់គ្រងអំពើពុករលួយ ។ ខ្ញុំមានបំណងផ្តោតការយកចិត្តទុកដាក់លើបញ្ហាសំខាន់ៗទាំងនេះនៅពេលធ្វើទស្សនកិច្ចរបស់ខ្ញុំនៅថ្ងៃខាងមុខមកកម្ពុជា ហើយសង្ឃឹមថារដ្ឋាភិបាលនឹងមានឆន្ទៈចូលរួមពិភាក្សាក្នុងន័យស្ថាបនាអំពីបញ្ហាទាំងនេះ ។

២៦. ខ្ញុំមានសេចក្តីរីករាយដែលមានឱកាសក្នុងពេលធ្វើទស្សនកិច្ចនេះ ដើម្បីគូសបញ្ជាក់អំពីគោលបំណងរបស់ខ្ញុំក្នុងការចូលរួមពិភាក្សាក្នុងន័យស្ថាបនាជាមួយរាជរដ្ឋាភិបាលកម្ពុជា និងផ្តល់ការជួយឧបត្ថម្ភក្នុងការជួយដោះស្រាយបញ្ហាសិទ្ធិមនុស្សមួយចំនួនដែលប្រទេសជាតិកំពុងប្រឈម ។ ខ្ញុំមានបំណងដើរតួនាទីជាស្ពានមួយរវាងរដ្ឋាភិបាល និងសង្គមស៊ីវិល ដើម្បីបង្កបរិយាកាសសហប្រតិបត្តិការជាជាងការប្រឈមមុខគ្នា សំរាប់ជាប្រយោជន៍នៃប្រជាជនកម្ពុជា ។ ខ្ញុំក៏មានបំណងជួយឧបត្ថម្ភដល់រដ្ឋាភិបាលក្នុងការលើកកំពស់មួយកំរិតថែមទៀត នៃភាពជ្រះស្រឡះពីគ្នាក្នុងការបែងចែកអំណាចរវាងស្ថាប័នធំៗទាំងបីរបស់រដ្ឋាភិបាល ក្នុងការពង្រឹងឯករាជ្យភាពតុលាការ និងក្នុងការបង្កើតគោលការណ៍ណែនាំថ្នាក់ជាតិមានតម្លាភាពស្តីពីការបណ្តេញចេញពីដីធ្លី ។

--------------